**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.....០២០.....សហវ.ខល

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការហាមឃាត់ការធ្វើអាជីវកម្មទូហ្គេម ( Gaming Machine ) ខុសច្បាប់

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកត់សំគាល់ឃើញថា បច្ចុប្បន្ននេះមានអាជីវករមួយចំនួន បាន និងកំពុងបើកធ្វើអាជីវកម្មទូហ្គេមដោយលួចលាក់នៅតាមទីប្រជុំជនសាធារណៈ ជាពិសេសនៅក្បែរសាលារៀនជាដើម ដែលទង្វើនេះបានធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់ស្រទាប់យុវវ័យ សិស្សានុសិស្សដែលកំពុងសិក្សា និងបង្កអសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈដល់សង្គមជាតិទាំងមូល ។

ដោយមានការណែនាំពីរាជរដ្ឋាភិបាលកម្ពុជា និងដើម្បីឈានទៅលុបបំបាត់ទាំងស្រុង នូវអាជីវកម្មទូហ្គេមខុសច្បាប់ទាំងនោះ សំដៅរក្សាអោយបាននូវសន្តិសុខ និងសណ្តាប់ធ្នាប់ល្អ នៅក្នុងរាជធានីភ្នំពេញ និងនៅទូទាំងខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជំរាបជូនដំណឹងដល់អាជីវករគ្រប់រូប ដែលកំពុងប្រកបអាជីវកម្មទូហ្គេមខុសច្បាប់ទាំងនោះ បញ្ឈប់សកម្មភាពអាជីវកម្មទូហ្គេមខុសច្បាប់របស់ខ្លួនជាបន្ទាន់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

ក្នុងករណីមិនអនុវត្តតាមការណែនាំខាងលើ គណៈកម្មការចម្រុះរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ រួមសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នឹងធ្វើការចុះបង្ក្រាប រឹបអូសសំភារៈអាជីវកម្មទូហ្គេមទាំងនោះ ហើយធ្វើការឃាត់ខ្លួនម្ចាស់អាជីវកម្ម រួចបញ្ជូនទៅតុលាការវិនិច្ឆ័យទោសទៅតាមច្បាប់ជាធរមាន ។

ទទួលបានសេចក្តីជូនដំណឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់អាជីវកម្មទូហ្គេមខុសច្បាប់ទាំងអស់ នឹងខិតខំអនុវត្តតាមការណែនាំខាងលើនេះ អោយ ទទួលបានប្រសិទ្ធភាពខ្ពស់ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- គណៈកម្មការចំរុះ "ដើម្បីមុខការ"
- គ្រប់សាលាខេត្ត-ក្រុង និងរាជធានីភ្នំពេញ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ